**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៥ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសភាពការណ៍ និងសំណូមពរចាំបាច់នៃការងារអភិវឌ្ឍន៍យោធា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១** : ត្រូវបានបង្កើតនាយកដ្ឋានអភិវឌ្ឍន៍ចំណុះផ្ទាល់ក្រសួងការពារជាតិ។

**មាត្រា ២** : នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ មានតួនាទីធ្វើជាសេនាធិការជូនក្រសួងការពារជាតិ ក្នុងវិស័យអភិវឌ្ឍន៍យោធា ដើម្បីកែប្រែជីវភាពរស់នៅរបស់កងទ័ព រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងមានភារកិច្ចដូចតទៅ :

- ដឹកនាំគ្រប់គ្រងស្ថាប័នអភិវឌ្ឍន៍ព្រមទាំងរោងចក្រ សហគ្រាស ក្រុមហ៊ុន សិប្បកម្ម កសិដ្ឋានចំណុះទាំងអស់នៃកងយោធពលខេមរភូមិន្ទតាមឋានានុក្រម ។

- ធ្វើផែនការមេអភិវឌ្ឍន៍វិស័យនានាមានកសិកម្ម កសិឧស្សាហកម្ម សិប្បកម្ម វារីវប្បកម្ម ជាដើម សម្រាប់អនុវត្តតាមតម្រូវការ និងលក្ខខណ្ឌជាក់ស្តែង (ភូមិសាស្ត្រ តម្រូវការទីផ្សារ លទ្ធភាពជាក់ស្តែង) ប្រកបដោយតម្លាភាព និងគណនេយ្យភាព រកចំណូលឲ្យបានច្រើន តាមដែលអាចធ្វើបាន រួមចំណែកលើកកម្ពស់ជីវភាពយោធិន នៃកងយោធពលខេមរភូមិន្ទ ទាំង ក្នុងអង្គភាព និងក្រៅអង្គភាព។
- គ្រប់គ្រងបានល្អ ចលន-អចលនទ្រព្យ ធនធានរបស់ស្ថាប័នអភិវឌ្ឍន៍ក្នុងកងយោធពល-ខេមរភូមិន្ទ។
- រួមចំណែកបណ្តុះបណ្តាលវិជ្ជាជីវៈ (ថ្នាក់មូលដ្ឋាន បឋម) នូវជំនាញកសិកម្ម សិប្បកម្ម។ល។ ដល់យោធិន ពិសេសយោធិនត្រៀមចូលនិវត្តន៍ និងយោធិនប្រភេទពីរ។
- សហការជាមួយបណ្តាសហគ្រាស ក្រុមហ៊ុន ស្ថាប័នរដ្ឋ និងឯកជន ជាតិ និងអន្តរជាតិ ធ្វើការ អភិវឌ្ឍន៍គម្រោងនានាដែលអាចធ្វើបានតាមច្បាប់រដ្ឋជាធរមាន។
- បូកសរុបរបាយការណ៍ស្តីពីលទ្ធផលការងារ នៃការអភិវឌ្ឍន៍ រាយការណ៍ជូនក្រសួងការ-ពារជាតិ។
- ពង្រឹង និងលើកកម្ពស់នូវវិន័យអត្តចរិត សីលធម៌រស់នៅ និងពង្រឹងកិត្យានុភាពរបស់កងទ័ព ឲ្យបានល្អប្រសើរ។
- ទទួលអនុវត្តនូវភារកិច្ចផ្សេងៗទៀតដែលក្រសួងការពារជាតិប្រគល់ឲ្យ។

នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិដឹកនាំដោយនាយកម្នាក់ និងនាយករងបីរូប ជាជំនួយការ។

**មាត្រា ៣** : នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ មានរចនាសម្ព័ន្ធចាត់តាំងដូចតទៅ :

- នាយក
- នាយករង
- លេខាធិការដ្ឋាន
- ផ្នែកបុគ្គលិក
- ផ្នែកហិរញ្ញវត្ថុ
- ការិយាល័យផែនការ អប់រំ និងបណ្តុះបណ្តាល
- ការិយាល័យទំនាក់ទំនងសាធារណៈ
- ការិយាល័បច្ចេកទេស និងគ្រប់គ្រងសម្ភារៈ
- ការិយាល័យកសិកម្ម
- ការិយាល័យសិប្បកម្ម
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- កសិដ្ឋាន

ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចការិយាល័យនីមួយៗរបស់នាយកដ្ឋានអភិវឌ្ឍន៍ នៃ ក្រសួងការពារជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សច្ចាប័នៈ** ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
**បានឃើញ និងឯកភាព**
លើរចនាសម្ព័ន្ធចាត់តាំងនាយកដ្ឋានអភិវឌ្ឍន៍
នៃក្រសួងការពារជាតិ
**នាយករដ្ឋមន្ត្រី**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# រចនាសម្ព័ន្ធចាត់តាំង
## នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ
## ចំនួនរួម 134នាក់

- **នាយក** 1
  - **នាយករង** 3
    - លេខាធិការដ្ឋាន 12
    - ផ្នែកបុគ្គលិក 3
    - ផ្នែកហិរញ្ញវត្ថុ 3
    - ការិយាល័យផែនការ អប់រំ និងបណ្តុះបណ្តាល 16
    - ការិយាល័យបច្ចេកទេស និងគ្រប់គ្រងសម្ភារៈ 15
    - ការិយាល័យកសិកម្ម 5
    - ការិយាល័យសិប្បកម្ម 5
    - ការិយាល័យ ទំនាក់ទំនងសាធារណៈ 5
    - មជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈ 33
    - កសិដ្ឋាន 33

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**